**សុន្ទរកថារបស់ ឯកឧត្តម HORINOUCHI Hidehisa**
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធគម្រោងពង្រីកមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក**
**ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦**

-សូមគោរព ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-សូមគោរព ឯកឧត្តមវេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-សូមគោរព ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស អស់លោក លោកស្រី

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមពិធីសម្ពោធ "គម្រោងពង្រីកមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក" ។

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណជូនដល់ ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រី ឯកឧត្តមវេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងមន្ត្រីរាជការរបស់ក្រសួងសុខាភិបាល ក៏ដូចជាមន្ត្រី-បុគ្គលិកនៃមជ្ឈមណ្ឌលនេះ ដែលបានរៀបចំពិធីនេះ។

រដ្ឋាភិបាលជប៉ុនបានជួយសាងសង់មជ្ឈមណ្ឌលនេះ នៅឆ្នាំ1995។ តាំងពីឆ្នាំនោះមក ជប៉ុនបានផ្តល់ជំនួយជាបន្តបន្ទាប់ដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រី-បុគ្គលិកសុខាភិបាល ដែលធ្វើការក្នុងវិស័យសុខភាពមាតា និងទារក ទាំងនៅក្នុងមជ្ឈមណ្ឌល និងតាមមន្ទីរពេទ្យខេត្តនានា។

យើងជឿរជាក់ថា សុខភាពមាតា និងទារក គឺពិតជាសំខាន់ណាស់ សម្រាប់ការលូតលាស់ប្រកបដោយសុខភាពល្អរបស់កុមារ។ ហេតុនេះហើយដែលរដ្ឋាភិបាលជប៉ុនបាននិងកំពុងផ្តល់អាទិភាពខ្ពស់នៅក្នុងវិស័យនេះតាំងពីយូរណាស់មកហើយ។

គម្រោងដែលយើងសម្ពោធនៅថ្ងៃនេះ បានចូលរួមជួយអភិវឌ្ឍន៍មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក តាមរយៈ៖ (1) ការសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលថ្មីមួយ និង (2) ការជួសជុលធ្វើអោយថ្មីឡើងវិញនូវអគារដែលមានស្រាប់និងការផ្គត់ផ្គង់ឧបករណ៍-
សំភារៈ។

ខ្ញុំសង្ឃឹមថា មជ្ឈមណ្ឌលបណ្តុះបណ្តាលថ្មីនេះនឹងជួយលើកស្ទួយដល់កម្រិតស្តង់ដារសេវាសុខាភិបាលនៅកម្ពុជា ហើយមជ្ឈមណ្ឌលដែលត្រូវបានពង្រីកហើយនេះ នឹងជួយផ្គត់ផ្គង់តម្រូវការរបស់ប្រជាជនកម្ពុជា អោយបានកាន់តែមានប្រសិទ្ធភាពជាងនេះ។

ជាចុងក្រោយ ខ្ញុំសូមបញ្ចប់សុន្ទរកថារបស់ខ្ញុំដោយសង្ឃឹមថាជំនួយរបស់ប្រជាជនជប៉ុននិងរដ្ឋាភិបាលជប៉ុននេះ នឹងជួយពង្រឹងទំនាក់ទំនងដ៏ជិតស្និទ្ធ និងមិត្តភាពរវាងប្រទេសកម្ពុជានិងប្រទេសជប៉ុន។

សូមអរគុណ។